# ស្រមោល
# IN THE SHADOW

ភាសាខ្មែរ-អង់គ្លេស
Bilingual (KH-EN)



## កម្រងស្នាដៃកំណាព្យខ្មែរបែបទំនើបនិយម
## The Collection of Cambodian Modernist Poetry

# គ្រូថ្នាក់ទីមួយ

ព្រះភិក្ខុ គៀន យិន ជ័យលាភីលេខ២

១ គ្រូថ្នាក់ទីមួយគ្រូឧត្តម
គ្រូចេះផ្សែផ្សំប្រសប់ឆ្នើម
គ្រូនេះជាគ្រូប្រធានដើម
ច្នៃផ្ដួចច្នៃផ្ដើមតួអក្ខរា។

២ ច្នៃស្នាមគំនូសទុកជាកេរ
បង្រៀនសរសេរផ្ដើម ក កា
បង្រៀនគូសអានបង្រៀនថា
ស្រៈ អ ស្រៈ អា គ ឃ ង។

៣ ផ្សំស្រៈផ្ញើជើងព្យាង្គតម្រូត
អក្ខរាស្រៈត្រូតជាគំនរ
ពន្យល់បកស្រាយឆាយរិះរក
លើកហេតុផលមកប្រៀបសេចក្ដី។

៤ សិស្សបានចំណេះលូតខ្ពស់ថ្កើង
សិស្សខ្លះបានឡើងដល់កុង្សីយ៍
ខ្លះជារាជការបម្រើដី
ខ្លះខាងកវីផ្នែកនិពន្ធ។

៥ សិស្សលូតបែកមែកជាសាខា
កើតពីអក្ខរាគាថាមន្ត
រៀនអានសរសេរជាកេរធន
បានមកពីគុណថ្នាក់ទីមួយ។

៦ គ្រូថ្នាក់ទីមួយគ្រូពិសេស
ពូនផ្សំចំណេះបណ្តុះត្រួយ
ចំណេះលូតខ្ពស់សិស្សផុតព្រួយ
គ្រូខំគាស់ស្មួយគ្មានសិស្សផ្តាប់។

៧ គ្រូដើមគ្រូគ្រឹះបណ្តុះផ្សាំ
តស៊ូរាប់ឆ្នាំយសអភ័ព្វ
ចំណាយជីវិតគេភ្លេចរាប់
គុណគ្រូល្អគាប់ធ្លាប់ជួយក្មេង៕

# ២៩

លោក ផុន ណាត់ ជ័យលាភីលេខ៣

១ ដើមឡើយជាដី សម្បូរស្មៅខ្ចី
និងព្រៃព្រឹក្សា អស់គោក្របី
បក្សីបក្សា អស់ម្រឹគខ្លៀវខ្លារ
ឆីស្មៅត្រួយខ្ចី។

២ អ្នកស្រែធ្វើស្រូវ ផលច្រើនពេកកូវ
រីករាយឥតបី ច្រើនឆ្នាំខួបខែ
ខ្លួនប្រែអស់អ្វី មិនដូចកាលថ្មី
មានដីជាតិច្រើន។

៣ មកដល់សព្វថ្ងៃ គេចេះកែច្នៃ
គេរីកចម្រើន គេព្រោះជីថ្មី
ឲ្យដីខ្ញុំថ្កើន ធ្វើស្រូវផលកើន
គាប់ចិត្តម្ចាស់ពិត។

៤ មិនបានប៉ុន្មាន ខ្លួនសោះរីងប្រាណ
ព្រោះជីវមរិត ម្ចាស់លែងធ្វើស្រែ
ផ្លាស់ផ្លូវគំនិត លក់ដូរមិនគិត
យកប្រាក់ដុល្លារ។

៥ អាសូរខ្លួនខ្ញុំ នឹកស្មានសុខុម
ប្រែទុក្ខខ្លោចផ្សា គេចាក់ស៊ីម៉ង់ត៍
សាងសង់វីឡា ពេញលើកាយា
ធ្ងន់ស្មើរក្សិណក្ស័យ។

៦ ដីភ័យបុកពោះ ខ្លាចអស់ដីព្រោះ
សំណង់ច្រើនក្រៃ ខ្លាចគេចាក់លុប
គេឈប់អាល័យ បើគេសម័យ
លែងចង់ជាន់ដី៕